

# គុណូបការៈ និង ភក្តីភាព

ឧប សៅ សង្ហា

ថ្ងៃទី ២ កុម្ភៈ ឆ្នាំ ២០១៦

អ្នកដឹកនាំ តែងជួបប្រទះ ជានិច្ច នូវ ការត្រូវរើស (dilemme) សហការី (ការិនី) ល្អប្រសើរដើម្បី ជួយ ធ្វើ កិច្ចការ របស់ខ្លួន ឬ ទទួលខុសត្រូវ លើ វិស័យ ណាមួយ។ បញ្ហាពិបាក ក្នុង ការជ្រើស រើស គឺ ត្រូវ សំរេច លើ លក្ខណៈ ពីរ យ៉ាងៈ គុណូបការៈ ឬ ភក្តីភាព។ ក្នុង ជម្រើស នេះ បើ ជា ការ ល្អ ត្រូវ មាន ទាំងពីរ លក្ខណៈ ព្រោះ ថាៈ

**គុណូបការៈ៖** មុខងារ (fonction) និមួយៗ វា មាន សមត្ថកិច្ច (compétence) នៃ មុខងារ និង សមត្ថភាព (capacité) របស់ អ្នក ដឹកនាំ ការងារ។ សមត្ថកិច្ច និង សមត្ថភាព នេះ ត្រូវ អ្នក ទទួល មុខងារ មាន ចាំបាច់ នូវ គុណូបការៈ ដែលជា មូលដ្ឋាននៃ ការពិសោធន៍ និង គុណ សម្បត្តិ របស់ បុគ្គល។ អ្នកដឹកនាំការងារ ប្រកប ដោយ គុណូបការៈ ត្រូវ មាន លក្ខន្តិកៈ ពីរ យ៉ាងៈ ទទួល ការតែងតាំង តាមច្បាប់ ឬ អ្នក មាន វិញ្ញាបនប័ត្រ (statut titulaire) និង លក្ខ ន្តិកៈ បុគ្គល ផ្ទាល់ ឬ គុណសម្បត្តិ របស់ ខ្លួនផ្ទាល់ (statut personnel)។ កត្តា ទាំងពីរនេះ ដែល នាំអោយ អ្នកដឹកនាំការងារ មាន ជម្មានុរូប ចំពោះ អ្នក ដ៏ទៃ និង អ្នកនៅក្រោមការដឹកនាំ របស់ខ្លួន ព្រោះ វា ជាតម្លៃ អត្តនោម័តិ (valeur subjective) សំរាប់ គេ យកមកធ្វើ ជា លក្ខណ វិនិច្ឆ័យ លើ តម្លៃ ជា អ្នកដឹកនាំការងារ។ ដូច្នេះ ជម្មានុរូប មិន ត្រឹមតែមាន តម្លៃ នៃ ច្បាប់ ឬ វិញ្ញាបនប័ត្រ ដែល ជា អាការក្រៅ (aspect extérieur) របស់ មុខងារ; លើសពី តម្លៃ នេះ វា មាន តម្លៃ នៃ គុណូបការៈ ដែល ជា អាការក្នុង របស់ អ្នកកាន់ការងារ។ សហការី (ការិនី) ដ៏ ប្រសើរ ក៏ ដូច អ្នកដឹកនាំ ខ្លួនឯងដែរ ត្រូវ ចាំបាច់ មាន គុណូបការៈ នេះឯង។

**ភក្តីភាព៖** ភក្តីភាព ជា កត្តា បន្ថែម លើ កត្តា គុណូបការៈ ទើប វា អាច មាន ប្រយោជន៍ដល់ ការងារ។ ភក្តីភាព មាន ពីរ ថ្នាក់៖ ភក្តីភាព នៅក្នុង ក្របខណ្ឌ ការងារ និង ភក្តីភាព ទៅលើ អ្នកដឹកនាំ ដែល ប្រគល់ ការទុកចិត្ត មកលើខ្លួន។ តែ ភក្តីភាព ត្រូវ ឋិត នៅក្នុង ក្របខ័ណ្ឌ ច្បាប់ ជានិច្ច ពុំនោះ ភក្តីភាព វា នឹងដូរ ធម្មជាតិ របស់ វា ពី គុណធម៌ ទៅជា អគុណធម៌។ ជា ទូទៅ អ្នក ដែល មាន គុណូបការៈ តែងតែ មាន សម្មាភក្តីភាព (loyauté juste) ព្រោះ វា មាន នៅក្នុង គុណសម្បត្តិ របស់ខ្លួន។ អ្នក ដែល គ្មាន គុណូបការៈ ភាគ ច្រើន ជា មនុស្ស ទុរជន ប្រើ ភក្តីភាព ជា ឧបករណ៍ សំរាប់ តែ បំរើ អត្តប្រយោជន៍ របស់ ខ្លួន។ អ្នកដឹកនាំ មាន សហ ការី (ការិនី) ច្រើន ជា មនុស្ស គ្មាន គុណូបការៈ ជ្រើសយកតែ មនុស្ស ដូចខ្លួន។ ការយក ញាតិ ឬ មិត្តភក្តិ ធ្វើជា សហការី (ការិនី) មិនសុទ្ធ ជា អំពើ មិន ល្អនោះឡើយ បើ ជន នោះ មាន គុ ណូបការៈ សំរាប់ ដឹកនាំ ការងារ។ តែ បើ ការជ្រើសរើស ផ្អែក តែ ទៅលើ លក្ខណវិនិច្ឆ័យ នៃ ភ ក្តីភាព តែមួយគត់ វា ប្រហែលជា នាំមក នូវ ទុក្ខ ច្រើនជាង នូវ សេចក្តីសុខ ព្រោះ ភក្តីភាព គ្មាន គុណូបការៈ ជា អាវុធ មុខពីរ។៚